WWF- កម្ពុជា
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧ ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្តីប្រកាសសារព័ត៌មាន** **សូមកុំចេញផ្សាយមុនម៉ោង ១១:៥៩នាទីយប់ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២**

# មន្ត្រីល្បាតជាឆ្នាំព្រៃឈើ និងជាអ្នកសង្គ្រោះសត្វព្រៃ

របាយការណ៍ស្តីអំពីការងារអនុវត្តន៍ច្បាប់ចងក្រងដោយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការ WWF បង្ហាញថាក្នុងរយៈពេល៦ឆ្នាំកន្លងទៅនេះ មន្ត្រីល្បាតបានជួយសង្គ្រោះជីវិតសត្វព្រៃសរុបចំនួន ២៦០ក្បាល ពីក្រញាំដៃអ្នកប្រម៉ាញ់សត្វព្រៃខុសច្បាប់ ហើយបានបន្តថែរក្សា និងការពារជម្រកព្រៃធម្មជាតិនៅក្នុងព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេចនៃតំបន់ព្រៃទេសភាពភាគខាងកើតប្រទេសកម្ពុជា។

ចេញផ្សាយនៅថ្ងៃទិវាមន្ត្រីល្បាតពិភពលោក របាយការណ៍ដែលមានចំណងជើងថា "ការពង្រឹងការអនុវត្តន៍ច្បាប់ប្រឆាំងនឹងបទល្មើសព្រៃឈើនៅក្នុងតំបន់ព្រៃទេសភាពភាគខាងកើតនៃប្រទេសកម្ពុជា" ពិពណ៌នាអំពីកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីល្បាតក្នុងការបង្ក្រាបការជួញដូរឈើ និងសត្វព្រៃខុសច្បាប់ ហើយបានឈានទៅរឹបអូសឈើប្រណិតបានចំនួនជាង ៣៥៨ម៉ែត្រគូបដែលមានតម្លៃជាទឹកប្រាក់ស្មើនឹងប្រមាណ១០០,០០០ដុល្លារអាមេរិក និងក្បាលសត្វព្រៃប្រភេទជិតផុតពូជជាច្រើនដូចជា ក្របីព្រៃ ទន្សោង ប្រើស និងកែះ។ របាយការណ៍នេះក៏បានលម្អិតផងដែរអំពីការឃាត់ខ្លួនអ្នកប្រម៉ាញ់ និងអ្នកជួញដូរខុសច្បាប់ជាច្រើននាក់ ព្រមទាំងបង្ហាញអំពីការជួយសង្គ្រោះជីវិតសត្វព្រៃប្រភេទជិតផុតពូជដូចជា ក្ងោក និងអណ្តើកព្រិច និងសត្វព្រៃប្រភេទកម្រដូចជា ត្រដក់តូច សំពោច ស្វាក្តាម និងស្វាត្រោស។ ក្នុងចំណោមសត្វដែលគេសង្គ្រោះបានទាំងនេះ ភាគច្រើនត្រូវបានគេប្រលែងចូលឲ្យទៅរស់នៅក្នុងព្រៃវិញ រីឯសត្វព្រៃមួយចំនួនតូចត្រូវបានគេបញ្ជូនទៅកាន់មជ្ឈមណ្ឌលជួយសង្គ្រោះសត្វព្រៃភ្នំតាម៉ៅដែលស្ថិតនៅក្បែរទីក្រុងភ្នំពេញ។

កាលពីចុងឆ្នាំ២០១១ គម្រោងសត្វខ្លានៃអង្គការ WWF បានផ្តល់ពានរង្វាន់ស្នាដៃឆ្នើមឲ្យទៅមន្ត្រីល្បាតនៅក្នុងខេត្តមណ្ឌលគិរីសម្រាប់ការងារតាមដាន និងពង្រឹងការអនុវត្តន៍ច្បាប់នៅក្នុងតំបន់ទីជម្រកសត្វខ្លា។ នៅថ្ងៃទិវាមន្ត្រីល្បាតពិភពលោក អ្នកដែលកំពុងបំពេញភារៈកិច្ចការពារព្រៃឈើរបស់ប្រទេសកម្ពុជាបង្ហាញពីទឹកចិត្តរបស់ខ្លួន។

លោក លាន ញ៉ូវ បានបំពេញតួនាទីខ្លួនជាមន្ត្រីល្បាតអស់រយៈពេលជាង១១ឆ្នាំនៅក្នុងព្រៃការពារមណ្ឌលគិរី និយាយថាការធ្វើការជាមន្ត្រីល្បាតមិនមែនជាកិច្ចការងាយស្រួលទេ ហើយតម្រូវឲ្យមានការប្តេជ្ញាចិត្ត និងការលះបង់ខ្ពស់ ប៉ុន្តែគាត់មានមោទនភាពចំពោះតួនាទីនេះ។ គាត់មានប្រសាសន៍ទៀតថា លទ្ធផលការងារដែលសម្រេចបានមិនមែនសម្រាប់តែមន្ត្រីល្បាតប៉ុណ្ណោះទេ ពោលគឺសម្រាប់ជាប្រយោជន៍ដល់ជាតិ និងប្រជាជនកម្ពុជាទាំងអស់។

លោក ញ៉ូវ បន្តថា៖ "ការងារបង្ក្រាបអ្នកកាប់ឈើ និងអ្នកបរបាញ់ខុសច្បាប់ ជាការងារប្រកបដោយគ្រោះថ្នាក់ និងមានភាពប្រឈមខ្ពស់បំផុត ប៉ុន្តែមន្ត្រីល្បាតទាំងអស់រួមទាំងខ្លួនខ្ញុំដែរ មិនមានអារម្មណ៍ភ័យខ្លាចពីព្រោះពួកយើងបានប្តេជ្ញាចិត្តចំពោះតួនាទីក្នុងការការពារព្រៃឈើ និងអភិរក្សសត្វព្រៃដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានឃើញមរតកធនធានធម្មជាតិដ៏មានតម្លៃរបស់កម្ពុជានាពេលអនាគត។"

លោក កែវ សុភគិ ជាប្រធានព្រៃការពារមណ្ឌលគិរីនៃរដ្ឋបាលព្រៃឈើ និយាយថាការឃាត់ខ្លួន និងទោសពិន័យជាប្រាក់មិនមែនជាដំណោះស្រាយសម្រាប់រយៈពេលយូរអង្វែងក្នុងការបញ្ឈប់ការបរបាញ់ខុសច្បាប់នោះទេ។ ការអប់រំប្រជាជនអំពីបទល្មើសព្រៃឈើ និងសត្វព្រៃ ព្រមទាំងផលវិបាកផ្សេងៗដែលបង្កឡើងដោយបទល្មើសព្រៃឈើ និងសត្វទាំងអស់

នេះចំពោះធនធានធម្មជាតិដែលប្រជាជនពឹងអាស្រ័យលើ អាចកែប្រែអាកប្បកិរិយា និងសកម្មភាពរបស់ពួកគេដែលនេះជាលទ្ធផលរយៈពេលយូរអង្វែង។"

លោក សុភគិ បន្តថា៖ "ការកែប្រែពីអ្នកបរបាញ់ខុសច្បាប់ឲ្យក្លាយទៅជាអ្នកការពារព្រៃឈើ និងសត្វព្រៃវិញ ជាជោគជ័យដ៏ធំមួយរួមចំណែកដល់ការងារគ្រប់គ្រងតំបន់ការពារក្នុងអំឡុងទសវត្សចុងក្រោយនេះ។"

តំបន់ព្រៃទេសភាពភាគខាងកើត ជាទីជម្រកដ៏សំខាន់សម្រាប់ការស្តារចំនួនសត្វខ្លាធំឡើងវិញនៅក្នុងប្រទេសកម្ពុជា និងជាទីជម្រកសម្រាប់សត្វទន្សោងដែលមានចំនួនច្រើនជាងគេនៅលើពិភពលោក និងសម្រាប់ថនិកសត្វធំៗដទៃទៀតដូចជា ដំរីអាស៊ី ក្របីព្រៃ ខ្ទីង រមាំង ព្រមទាំងសត្វស្លាបធំៗដូចជា ត្រយ៉ងយក្ស ត្រយ៉ងចង្កំកស ក្ងោក និងសត្វត្មាត។ ទោះជាយ៉ាងនេះក៏ដោយ របាយការណ៍បានពិពណ៌នាផងដែរអំពីកត្តាគំរាមកំហែងធំៗចំពោះតំបន់ព្រៃទេសភាព និងជីវចម្រុះ រួមមានការកាប់ឈើខុសច្បាប់ ការទន្ទ្រានដីព្រៃ ការបរបាញ់ និងការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់។

ដោយសារកិច្ចខិតខំប្រឹងប្រែងផ្នែកពង្រឹងការអនុវត្តន៍ច្បាប់របស់មន្ត្រីល្បាតមានកម្រិតខ្ពស់ រាជរដ្ឋាភិបាលកម្ពុជានឹងមានលទ្ធភាពក្នុងការធានាការការពារបាននូវតំបន់ទេសភាពព្រៃល្បោះដ៏ធំ ហើយតភ្ជាប់គ្នា។ ទោះជាយ៉ាងណាក៏ដោយ ចំនួនមន្ត្រីល្បាតនាពេលបច្ចុប្បន្ននេះ នៅមិនទាន់គ្រប់គ្រាន់ដើម្បីអនុវត្តការងារដើរល្បាតនៅក្នុងតំបន់ព្រៃដែលមានផ្ទៃក្រលាប្រមាណជិត ៦,០០០គីឡូម៉ែត្រការ៉េឲ្យបានប្រសិទ្ធិភាពខ្ពស់នោះទេ។ ជាងនេះទៀត ការជួញដូរសត្វព្រៃ និងឈើខុសច្បាប់នៅតំបន់ព្រំប្រទល់កម្ពុជា និងវៀតណាម ជាឧបសគ្គបន្ថែមមួយសម្រាប់ការពង្រឹងការងារអនុវត្តន៍ច្បាប់នៅក្នុងតំបន់នេះ។

កញ្ញា មីហ្សែល អូវិន នាយកស្តីទីនៃអង្គការ WWF និយាយថា៖ "ឈើប្រណិតជាង ១,០០០កំណាត់ដែលត្រូវបានរឹបអូសនៅតំបន់ព្រំប្រទល់ចាប់តាំងពីឆ្នាំ២០១០ ប្រហែលគ្រាន់តែជាចំណែកមួយប៉ុណ្ណោះនៃសកម្មភាពជួញដូរខុសច្បាប់នៅតំបន់នេះ។" កញ្ញា មីហ្សែល បន្តថា៖ "គេត្រូវពង្រឹងការដាក់ទោសចំពោះជនល្មើសដើម្បីធ្វើឲ្យអ្នកជួញដូរឈើ និងសត្វព្រៃខុសច្បាប់ខ្លាចរអា ។"

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:**
លោក អេង ម៉េងអ៊ី
ការិយាល័យសារពត៌មាន និងកិច្ចការសាធារណៈ
អង្គការ WWF-កម្ពុជា
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៨ ០៣៤
អ៊ីមែល: mengey.eng@wwf.panda.org

**ពត៌មានសម្រាប់អ្នកនិពន្ធ:**

- សូមអានអត្ថបទពត៌មានអំពីមន្ត្រីល្បាត សូមទៅកាន់គេហទំព័រ www.cambodia.panda.org និង www.panda.org/tigers/card4tigers ។ គេហទំព័រស្តីពីមន្ត្រីល្បាតទាំងពីរនឹងបង្ហាញជាសាធារណៈនូវថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ដែលជាថ្ងៃប្រារព្ធទិវាមន្ត្រីល្បាតពិភពលោក។

- ទិវាមន្ត្រីល្បាតពិភពលោកត្រូវបានគេប្រារព្ធជាលើកដំបូងបង្អស់នៅក្នុងឆ្នាំ២០០៧ដើម្បីរំលឹក និងថ្លែងអំណរគុណដល់មន្ត្រីល្បាតជាច្រើនដែលបានពលីជីវិត និងរងរបួសក្នុងពេលបំពេញកាតព្វកិច្ចរបស់ខ្លួន។ គេប្រារព្ធទិវានេះក៏ដើម្បីលើកម្កស់តម្លៃការងាររបស់មន្ត្រីល្បាតនៅក្នុងការការពារតំបន់ទេសភាពសត្វព្រៃ និងព្រៃឈើនៅលើសាកលលោកផងដែរ។

- អង្គការ WWF និងរាជរដ្ឋាភិបាលកម្ពុជា ធ្វើការគ្រប់គ្រងរួមគ្នានូវតំបន់ការពារចំនួនពីរគឺ ព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេច ដែលមានផ្ទៃក្រលាសរុបប្រមាណ ៦,០០០ គីឡូម៉ែត្រការ៉េ ដើម្បីអភិរក្សពពួកថនិកសត្វប្រភេទជិតផុតពូជដូចជា ខ្លាធំ ដំរីអាស៊ី ក្របីព្រៃ ទន្សោង ខ្ទីង រមាំង ព្រមទាំងពពួកសត្វស្លាបប្រភេទជិតផុតពូជជាច្រើនទៀត។ គម្រោងមានទិសដៅថែរក្សា និងការពារបណ្តុំព្រៃទេសភាពដែលនៅសេសសល់ចុងក្រោយនេះ ឱ្យមានសភាពស្រស់ស្អាត ហើយតភ្ជាប់គ្នា ព្រមទាំងជួយប្រជាជនក្នុងការការពារធនធាន សត្វព្រៃ និងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ពួកគេប្រកបដោយនិរន្តរភាព។

- អង្គការ WWF ផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមចល័តបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃប្រចាំនៅខេត្តមណ្ឌលគិរីដែលក្រុមនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៩។ ដឹកនាំប្រតិបត្តិការណ៍ដោយរដ្ឋបាលព្រៃឈើ ក្រុមចល័តបង្ក្រាប មានសមត្ថកិច្ចបង្ក្រាបរាល់អំពើល្មើសដែលកើតឡើងនៅទូទាំងខេត្តមណ្ឌលគិរី ហើយមានសមាសភាពមន្ត្រីមកពីក្រសួងបរិស្ថាន នគរបាល និងកងរាជអាវុធហត្ថនៃខេត្តមណ្ឌលគិរី។ ក្រៅពីក្រុមចល័តបង្ក្រាបនេះ ក្រុមល្បាត ដែលចំនួនបុគ្គលិកសរុបជាង ៣០នាក់ទៀត កំពុងធ្វើការងាររបស់ខ្លួនជាប្រចាំនៅក្នុងព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេច។